ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឆ្ពោះទៅកាន់ការបង្កើត
# យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់
# ជនក្រីក្រ និងងាយរងគ្រោះ នៅកម្ពុជា

ឯកសារមូលដ្ឋានរៀបចំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍

ភ្នំពេញ

ខែឧសភា ឆ្នាំ២០១០

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

# យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ

**ខែមិថុនា ឆ្នាំ២០១០**

១. ការគាំពារសង្គម គឺជាគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌និងប្រសិទ្ធភាព ដំណាក់កាលទី២ ហើយបានបានរំលេចយ៉ាងច្បាស់ថែមទៀតនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចុប្បន្នកម្ម ២០០៩-២០១៣ ព្រមទាំងបានអនុម័ត និងចុះហត្ថលេខាលើ លិខិតបទដ្ឋាន ជាក្របខណ្ឌច្បាប់គតិយុត្ត ព្រមទាំងសិទ្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិជាច្រើន។

២. ភាពចាំបាច់នៃការរៀបចំឱ្យមានជាយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ គឺដើម្បីជំរុញឱ្យរីកចម្រើន បង្កើនប្រសិទ្ធភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។ វិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោក និងការឡើងថ្លៃទំនិញ ប្រេង បានជះឥទ្ធិពលអវិជ្ជមាន ជាពិសេសលើក្រុមជនក្រីក្រនិងជនងាយរងគ្រោះ ហើយបានរាំងដំណើរ ធ្វើឱ្យយឺតយ៉ាវដល់ការធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា ។

៣. ដើម្បីឆ្លើយតបទៅនឹងកិច្ចការជាបន្ទាន់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិភពលោក រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសព្វរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានចាត់វិធានការណ៍យ៉ាងមុតស្រួច ទាំងក្នុងក្របខ័ណ្ឌជាគោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីទប់នឹងវិបត្តិនេះ និងបានដាក់ចេញនូវកញ្ចប់នៃវិធានការណ៍ គោលនយោបាយសម្របសម្រួល ធានា

ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចទូទៅ ជាពិសេសនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ កសិកម្ម និងសំណង់ និងប្រព័ន្ធសុវត្ថិភាពសង្គម។ យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី២ បានលើកឡើងពីការជម្រុញអភិបាលកិច្ចល្អនៅក្នុងការផ្តល់សុវត្ថិភាពសង្គម តាមរយៈការពង្រឹងស្ថាប័ន និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងការពង្រីកបន្ថែមសេវាសង្គមកិច្ច និងកម្មវិធីសង្គ្រោះបន្ទាន់ឱ្យបានកាន់តែទូលំទូលាយ។ តាមរយៈការធ្វើវិនិយោគពង្រឹង ការគាំពារសង្គម រាជរដ្ឋាភិបាលកម្ពុជា មានទិសដៅ និងធ្វើឱ្យសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រផង និងលទ្ធភាពឆ្លើយតបដោះស្រាយបញ្ហាប្រឈមនឹងហានិភ័យ ដែលអាចកើតមានឡើងជាយថាហេតុផង។ អាស្រ័យហេតុនេះ យុទ្ធសាស្រ្តគាំពារសង្គមនេះ គឺរៀបចំឡើងដើម្បីគាំទ្រដល់ការធានាសុវត្ថិភាព សន្តិសុខសង្គម សេដ្ឋកិច្ច របស់ប្រជាពលរដ្ឋ ជាមូលដ្ឋាននៃការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌ នៃការបែងចែកកំណើនសេដ្ឋកិច្ច ។

៤. ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្ត ក្របខណ្ឌនៃយុទ្ធសាស្រ្តគាំពារសង្គមសម្រាប់ក្រុមជនក្រីក្រ និងជនងាយរងគ្រោះ បានត្រូវរៀបចំតាក់តែងឡើង ដោយមានការថ្លឹងថ្លែង រវាងដំណោះស្រាយដើម្បីការកាត់បន្ថយភាពក្រីក្ររ៉ាំរ៉ៃផង ជួយជនក្រីក្រឱ្យមានសមត្ថភាពឆ្លើយតបនូវហានិភ័យ ដែលកើតឡើងដោយសារហេតុផលសង្គម សេដ្ឋកិច្ច និងបរិស្ថាន ព្រមជាមួយការលើកកំពស់សមត្ថភាពធនធានមនុស្ស ដើម្បីអាចចៀសផុតពីភាពក្រីក្រដោយខ្លួនឯងនាពេលអនាគត។ យុទ្ធសាស្រ្តគាំពារសង្គម បានរៀបចំឡើងដោយឈរលើគោលការជាមូលដ្ឋាន បី ដូចខាងក្រោម :

- ការជួយគាំទ្រដល់ក្រុមជនដែលក្រីក្របំផុត និងក្រុមជនរងគ្រោះបន្ទាន់ ដែលមិនមានលទ្ធភាពដោះស្រាយដោយខ្លួនឯង បើមិនមានការផ្តល់ជំនួយ ឬសេវាឧបត្ថម្ភសង្គមកិច្ចនានា,
- ការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យគ្រប់ប្រភេទ ដែលអាចរុញឱ្យធ្លាក់ទៅក្នុងភាពកាន់តែក្រីក្រ តោកយ៉ាកថែមទៀត, និង
- ការទ្រទ្រង់ដល់ជនក្រីក្រ ឱ្យមានសមត្ថភាពអាចឆ្លងផុតពីភាពក្រីក្រ តាមរយៈការកសាងមូលធនមនុស្ស និងការពង្រីកកាលានុវត្តភាពរបស់ពួកគេនាពេលអនាគត។

## ដំណើរការនៃការរៀបចំចងក្រងយុទ្ធសាស្រ្តគាំពារសង្គម

៥. នៅក្នុងកិច្ចប្រជុំវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ កាលពីថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០០៨ នៅទីក្រុងភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានធ្វើការកត់សម្គាល់ឃើញនូវវឌ្ឍនភាពជាច្រើន

ដែលត្រូវបានសម្រេចឡើងនាពេលកន្លងមក ពិសេសក្នុងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែស្របពេលជាមួយគ្នាក៏បានទទួលស្គាល់ថា ផ្នែកខ្លះនៃប្រជាជនកំពុងស្ថិតនៅក្នុងស្ថានភាព ដែលងាយនឹងទទួលរងគ្រោះពីវិបត្តិសង្គម និងសេដ្ឋកិច្ចមួយចំនួន ដែលអាចរុញច្រានពួកគេឱ្យធ្លាក់ទៅក្នុងភាពក្រីក្រ។ ទាក់ទងនឹងបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ បានព្រមព្រៀងក្នុងការពិនិត្យឡើងវិញនូវវិសាលភាព នៃប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គម ក្នុងការទប់ទល់នឹងហានិភ័យនៃអស្ថេរភាពតម្លៃអាហារ និងកល្បិយុគសេដ្ឋកិច្ចទៅលើជីវភាពរស់នៅរបស់ប្រជាជនក្រីក្រនិងជនដែលងាយរងគ្រោះ។ ជំហានដំបូងនៃការងារនេះ គឺការរៀបចំឡើងនូវកិច្ចការវិភាគទូទៅ ក្នុងការកំណត់នូវវិសាលភាពនៃប្រព័ន្ធសុវត្ថិភាពសង្គមដែលមានស្រាប់ និងការកំណត់ទិសដៅគោលនយោបាយ ព្រមទាំងជំរើសយុទ្ធសាស្ត្រសម្រាប់ការបង្កើតឡើងនូវប្រព័ន្ធសុវត្ថិភាពសង្គមមួយ ដែលមានលក្ខណៈចម្រុះនិងជាប្រព័ន្ធ និងស្របតាមស្ថានភាពសង្គម-សេដ្ឋកិច្ចនៅកម្ពុជា។

៦. ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវបានផ្តល់ភារកិច្ច ដើម្បីធានាឱ្យមានប្រសិទ្ធភាព ក្នុងយន្តការសម្របសម្រួលអន្តរក្រសួង ដោយមានការចូលរួមពីក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ហើយមានសកម្មភាពការងារផ្តោតលើការផ្តល់កម្មវិធីប្រព័ន្ធសុវត្ថិភាពសង្គមទៅឱ្យជនងាយរងគ្រោះ និងជនក្រីក្រ។ ក្នុងន័យនេះផងដែរ ក្រុមប្រឹក្សាស្តារអភីវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក៏មានភារកិច្ច ដើម្បីរៀបចំយុទ្ធសាស្ត្រនានា ដែលឈរលើលក្ខណៈទូលំទូលាយ ដោយមានការគ្របដណ្តប់លើវិស័យទាំងអស់ នៃការអភិវឌ្ឍន៍សកម្មភាពសេដ្ឋកិច្ចជនបទ និងដើម្បីសម្របសម្រួល តាមដាន និងវាយតម្លៃការអនុវត្តនូវយុទ្ធសាស្ត្រខាងលើនេះ ក្នុងន័យប្រឹងប្រែងរបស់វិស័យឯកជន តម្រូវឱ្យមានការពង្រីកបន្ថែមទៀតឱ្យដល់តំបន់ដាច់ស្រយាល ដែលមិនទាន់មានសកម្មភាពគាំទ្រ ក៏ប៉ុន្តែមានភាពក្រីក្រខ្ពស់។

៧. នាពាក់កណ្តាលដំបូងនៃឆ្នាំ២០០៩ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានការគាំទ្រពីសំណាក់ក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ បានធ្វើការរួមគ្នាដើម្បីស្ថាបនានូវការឯកភាពគ្នាលើទស្សនទានគន្លឹះ និងទិសដៅទូលំទូលាយ សម្រាប់ការបង្កើតគោលនយោបាយប្រព័ន្ធសុវត្ថិភាពសង្គម។ លទ្ធផលនៃការរកឃើញ និងអនុសាសន៍នានាត្រូវបានបង្ហាញក្នុងឱកាសវេទិកាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្រោមប្រធានបទប្រព័ន្ធសុវត្ថិភាពសង្គមនៅកម្ពុជា នាថ្ងៃទី៦-៧ ខែកក្កដា ឆ្នាំ២០០៩។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានផ្តល់សុន្ទរកថាបិទអង្គវេទិកា ដោយបានសង្កត់ធ្ងន់ថា ការពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់ក្រុមជនងាយរងគ្រោះ គឺជាយុទ្ធសាស្ត្រចំបងមួយរបស់រាជរដ្ឋាភិបាល ក្នុងការទប់ទល់នឹងបច្ច័យអវិជ្ជមាន និងហានិភ័យនានា ដែលបានកើតមានពីកល្បិយុគសេដ្ឋកិច្ចសកល។ តួនាទីស្នូលនៃសំណាញ់សុវត្ថិភាពសង្គម គឺការពារដល់ក្រុមជនងាយទទួលរងគ្រោះ និងដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិ ក៏ដូចជាការកសាងមូលធនមនុស្ស និងសង្គម សម្រាប់

ការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច។ នៅពាក់កណ្តាលចុងក្រោយនៃឆ្នាំ២០០៩ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានធ្វើការរៀបចំបង្កើតនូវយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់កម្ពុជា ដោយពិចារណាទៅលើការកំណត់អាទិភាពសម្រាប់ កម្មវិធីប្រព័ន្ធសុវត្ថិភាពសង្គមនៅឆ្នាំ ២០១០។

## ចក្ខុវិស័យ គោលដៅ និងគោលបំណង

៨. យុទ្ធសាស្ត្រគាំពារសង្គមនេះ បានកំណត់ជាចក្ខុវិស័យថា **ប្រជាជនកម្ពុជារាល់រូប ពិសេសជនក្រីក្រ និងងាយរងគ្រោះ នឹងបានទទួលផលប្រយោជន៍ពីបណ្តាញសុវត្ថិភាពសង្គម និងរបបសន្តិសុខសង្គម ឱ្យកាន់តែប្រសើរឡើង ដែលជាផ្នែកនៃប្រព័ន្ធគាំពារសង្គម ដ៏មានប្រសិទ្ធិភាព សមស្របដែលអាចអនុវត្ត និងមាននិរន្តរភាព**។ គោលដៅចំបងនៃយុទ្ធសាស្ត្រគាំពារសង្គម គឺ **ជនក្រីក្រ និង ជនងាយរងគ្រោះកម្ពុជានឹងទទួលការគាំពារកាន់តែប្រសើរឡើង ពី ភាពក្រីក្ររ៉ាំរ៉ៃនិងភាពអត់ឃ្លាន វិបត្តិ ភាពខ្វះខាត និងមូលហេតុសង្គម និងទទួលបានប្រយោជន៍ពីការធ្វើ វិនិយោគលើធនធានមូលធនមនុស្សរបស់ពួកគេ។** គោលបំណងចម្បង៧ នៃយុទ្ធសាស្ត្រគាំពារសង្គម រួមមាន :

១. ឆ្លើយតបនូវតម្រូវការមូលដ្ឋានរបស់ជនក្រីក្រ និងជនងាយរងគ្រោះ ក្នុងស្ថានភាពរងគ្រោះអាសន្ន និងកល្បិយុគ

២. កាត់បន្ថយភាពក្រីក្រ និងងាយរងគ្រោះនៃកុមារ និងមាតា និង បង្កើនការអភិវឌ្ឍន៍ធនធានមនុស្សរបស់ពួកគេ

៣. ឆ្លើយតបនូវភាពខ្វះការងារ និងភាពគ្មានការងារដែលកើតមានឡើង តាមរដូវកាល និងផ្តល់នូវឱកាសជូនសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ របស់ពួកគេ

៤. បង្កើនការថែទាំសុខភាពដែលអាចទទួលយកបាន ដល់ជនក្រីក្រ និងងាយរងគ្រោះ

៥. បង្កើនការគាំពារសង្គមសម្រាប់ជនងាយរងគ្រោះពិសេសមួយចំនួន ។

## ផ្តោតការយកចិត្តទុកដាក់លើជនក្រីក្រ និងជនងាយរងគ្រោះ

៩. ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលដៅ និងគោលបំណង នៅក្នុងដំណាក់កាលខ្លី និងមធ្យម យុទ្ធសាស្ត្រគាំពារសង្គមបានកំណត់សកម្មភាពអាទិភាពនៃការរៀបចំឡើងនូវបណ្តាញសុវត្ថិភាពសង្គម ដែលមានប្រសិទ្ធិភាព និងនិរន្តរភាព ដោយផ្តោតគោលដៅ ទៅលើជនក្រីក្រ និងជនងាយរងគ្រោះ ដោយមាននូវសេវាកម្មសុខមាលភាពសង្គមបន្ថែម សម្រាប់ជនងាយរងគ្រោះពិសេសមួយចំនួន។

**វិសាលភាពនៃយុទ្ធសាស្ត្រគាំពារសង្គមដោយផ្តោតលើជនក្រីក្រ និងងាយរងគ្រោះ**




# កិច្ចការអនុវត្តយុទ្ធសាស្ត្រគាំពារសង្គម

១០. តាមពិតទៅកម្មវិធីសុវត្ថិភាពសង្គម មិនមែនការងារថ្មីសំរាប់កម្ពុជាទេ ប៉ុន្តែការយល់ដឹងពីទស្សនៈ និង អត្ថន័យមានការយល់ផ្សេងៗពីគ្នា។ កម្ពុជាបានអនុវត្តកម្មវិធី និងគម្រោងទាំងនោះជាច្រើនមកហើយ ដើម្បីធ្វើសមារណហកម្ម និតិសម្បទា និងដើម្បីលើកកំពស់សន្តិសុខស្បៀង ឆ្លើយតបទៅនឹងស្ថានភាពសង្គ្រោះបន្ទាន់ផង និងដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រផង។ ប្រព័ន្ធបណ្តាញសុវត្ថិភាពសង្គម ដែលជាផ្នែកសំខាន់នៃយុទ្ធសាស្ត្រគាំពារសង្គម បានចងក្រងសមស្របនៅក្នុងបរិបទកម្ពុជាមានលក្ខណៈចម្រុះ និងជាប្រព័ន្ធដែលរាជរដ្ឋាភិបាលអាចឆ្លើយតបភ្លាមៗតាមសភាពការ និងប្រភេទនៃហានិភ័យ

ទាន់ពេលវេលា និងស៊ីសង្វាក់គ្នា រវាងស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ដែលមានប្រសិទ្ធភាព និងមានភាពស័ក្តសិទ្ធសម្រាប់សម្រាប់រយៈពេលបន្ទាន់ ពេលមធ្យម និងរយៈពេលវែង។

១១. ការសម្រេចឱ្យបាននូវកម្មវត្ថុទាំងនេះ ទាមទារនូវ ១. ពង្រីកបន្ថែម និងធ្វើសុខុដុមនីយកម្មលើអន្តរាគមន៍ការគាំពារសង្គមដែលមានស្រាប់ និង ២. ចាប់អនុវត្តនូវកម្មវិធីថ្មី ដើម្បីគ្របដណ្តប់លើចន្លោះប្រហោងនៃការគាំពារសង្គម។ ក្នុងលក្ខណៈជាអាទិភាពចម្បង កម្មវិធីការងារសាធារណៈការក្នុងការផ្តល់ឱកាសការងារ និងប្រាក់ចំណូលសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ នឹងត្រូវបង្កើតបន្តឡើង។ គម្រោងផ្ទេរសាច់ប្រាក់សម្រាប់គ្រួសារក្រីក្រដែលមានកូនច្រើន ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងការសិក្សាអប់រំ នឹងត្រូវអនុវត្តដើម្បីផ្តល់ការគាំពារដល់កុមារ ពីឥទ្ធិពលក្នុងរយៈពេលខ្លីនៃកល្បិយុគនាពេលបច្ចុប្បន្ន និងការធ្វើអោយប្រសើរឡើងនូវការអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងរយៈពេលវែង។

១២. មូលនិធិសមធម៌សុខភាព ការផ្តល់ស្បៀងអាហារនៅសាលា អាហារូបករណ៍ និងកម្មវិធីសំណង់សាធារណៈ ជាប្រភេទកម្មវិធីដែលបានឆ្លើយតបរួចហើយទៅនឹងភាពងាយរងគ្រោះចម្បងៗនានា ដែលជនក្រីក្របានជួបប្រទះ ហើយកំពុងតែផ្តល់នូវប្រសិទ្ធិភាព។ ទោះជាយ៉ាងណាកម្មវិធីមួយចំនួន ឧទាហរណ៍កម្មវិធីសំណង់សាធារណៈ មានទំនោរទៅកាន់ការអនុវត្តដោយដៃគូអភិវឌ្ឍន៍ លើមូលដ្ឋានបណ្តោះអាសន្នដោយពុំមាននូវការសម្របសម្រួលគ្រប់គ្រាន់ ហើយភាគច្រើន និរន្តរភាពក្នុងដំណាក់កាលមធ្យមរបស់កម្មវិធីទាំងនេះត្រូវពិចារណាឡើងវិញ។ នៅក្នុងការពង្រីកទំហំនៃការអន្តរាគមន៍ទាំងនេះ ការធ្វើសុខុដុមនីយកម្មលើដំណើរការ និងការធានាការផ្តល់ហិរញ្ញប្បទានជាទៀងទាត់ ក៏ដូចជាការធានា ឱ្យបាននូវនិរន្តរភាពក្នុងដំណាក់កាលមធ្យម គឺជាប្រការដ៏សំខាន់ចាំបាច់បំផុត។ បន្ថែមលើនេះទៀត ការគ្របដណ្តប់នៃកម្មវិធីទាំងឡាយដែលមានស្រាប់ នឹងត្រូវវិភាគវាយតម្លៃជាថ្មី ហើយតម្រង់ឱ្យត្រូវគ្នាជាមួយនឹងកម្រិតនៃភាពក្រីក្រ និងភាពងាយរងគ្រោះនៅតាមបណ្តាខេត្ត និងស្រុក។

១៣. បញ្ហាប្រឈមនៅក្នុងការគាំពារសង្គមដែលមានស្រាប់ សម្រាប់ជនក្រីក្រ និងងាយរងគ្រោះ នឹងត្រូវលើកឡើងដោយការចាប់អនុវត្តកម្មវិធីថ្មី ដែលមានទិសដៅដល់ទាំងការជួយសម្រាលភាពក្រីក្ររ៉ាំរ៉ៃ និងការបង្កើនមូលធនមនុស្ស ដូចជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដែលផ្តោតលើការធ្វើអោយប្រសើរឡើងនូវលទ្ធផលនៃអាហារូបត្ថម្ភមាតា និងកុមារ សុខភាព និង ការអប់រំ និងការកាត់បន្ថយពលកម្មកុមារ ក៏ដូចជាការផ្តល់កម្មវិធីផ្តល់ឱកាសថ្មី ដែលបង្កើនការអភិវឌ្ឍន៍ជំនាញសម្រាប់យុវជនដែលស្ថិតនៅក្រៅសាលា និងផ្តល់ការទ្រទ្រង់ដល់ពលករជាកុមារឱ្យវិលត្រឡប់មកចូលរួមក្នុងប្រព័ន្ធសាលារៀនជាថ្មីវិញ។ អន្តរាគមន៍ថ្មីៗទាំងនេះនឹងត្រូវចាប់អនុវត្តសាកល្បង វាយតម្លៃ និងពង្រីកបន្ថែម ដោយពឹងផ្អែកលើប្រសិទ្ធិភាព និងនិរន្តរភាព។

១៤. យោងលើអាទិភាពនៃយុទ្ធសាស្រ្តគាំពារសង្គម តារាងខាងក្រោម គឺជាឧបករណ៍សក្តិសមសម្រាប់ការអនុវត្តក្នុងដំណាក់កាលមធ្យម :

**វិស័យអាទិភាព គោលបំណង និងជម្រើសឧបករណ៍កម្មវិធីការគាំពារសង្គមសម្រាប់ដំណាក់កាលមធ្យម**

| វិស័យអាទិភាព និងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា (គអសគ) ដែលពាក់ព័ន្ធ | គោលបំណង | ជម្រើសសម្រាប់ដំណាក់កាលមធ្យម សម្រាប់ឧបករណ៍នៃកម្មវិធី |
|---|---|---|
| ឆ្លើយតបនូវតម្រូវការមូលដ្ឋាន របស់ជនក្រីក្រ និងជនងាយរងគ្រោះ ក្នុងស្ថានភាពរងគ្រោះ អាសន្ន និងកល្លិយុគ (គអសក ១, ៩) | ១. ជនក្រីក្រ និងងាយរងគ្រោះ ទទួលការទ្រទ្រង់ រួមមានស្បៀង អនាម័យ ទឹក និងទីជម្រក ... ដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន របស់ពួកគេ ក្នុងអំឡុងពេលនៃគ្រោះអាសន្ន និងកល្លិយុគ | - ការចែកចាយស្បៀងដោយមានគោលដៅ<br>- ការចែកចាយសម្ភារៈផលិតកម្មកសិកម្ម<br>- ប្រតិបត្តិការគាំទ្រក្នុងគ្រោះអាសន្នផ្សេងៗ |
| កាត់បន្ថយភាពក្រីក្រ និងងាយរងគ្រោះនៃកុមារ និងមាតា និងបង្កើនការអភិវឌ្ឍន៍ធនធានមនុស្សរបស់ពួកគេ (គអសក ១, ២, ៣, ៤, ៥) | ២. កុមារ និងមាតាក្រីក្រ និងងាយរងគ្រោះ ទទួលផលប្រយោជន៍ ពីបណ្តាញសុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនការអភិវឌ្ឍន៍ មូលធនមនុស្ស ដោយការធ្វើអោយប្រសើរឡើង នូវអាហារូបត្ថម្ភ សុខភាពមាតា និងកុមារ ការលើកកំពស់ការអប់រំ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ | - ការឧបត្ថម្ភជាសាច់ប្រាក់ ប័ណ្ណ ស្បៀង ឬជាសម្ភារៈ សម្រាប់កុមារ និងស្ត្រី ឆ្ពោះទៅកាន់កម្មវិធីមួយមានលក្ខណៈចម្រុះ (ឧទាហរណ៍ ការឧបត្ថម្ភ សាច់ប្រាក់ផ្តោតលើអាហារូបត្ថម្ភមាតា និងកុមារ ការឧបត្ថម្ភសាច់ប្រាក់ដើម្បីបង្កើនការអប់រំ និងកាត់បន្ថយពលកម្មកុមារ)<br>- សេវាកម្មដល់ទីកន្លែង និងកម្មវិធីផ្តល់ឱកាសជាថ្មីដល់យុវជនក្រៅសាលា និងទ្រទ្រង់ដល់សេវាកម្មសុខមាលភាពសង្គម<br>- ការឧបត្ថម្ភអាហារបំប៉ន ដល់ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅកូន និងកុមារ<br>- ការផ្តល់ស្បៀងនៅសាលា របបស្បៀងយកទៅផ្ទះ |
| ឆ្លើយតបនូវភាពខ្វះការងារ និងភាពគ្មានការងារ ដែលកើតមានឡើងតាមរដូវកាល និងផ្តល់នូវឱកាសជូនសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ (គអសក ៤, ៥, ៦) | ៣. ជនក្រីក្រ និងងាយរងគ្រោះដែលមានអាយុស្ថិតក្នុងវ័យប្រកបការងារ ទទួលផលប្រយោជន៍ ពីកាលានុវត្តន៍ភាពការងារ ដើម្បីធានាប្រាក់ចំណូល ស្បៀង និងជីវភាពរស់នៅ ព្រមទាំងផ្តល់វិភាគទាន ដល់ការបង្កើតទ្រព្យធនហេដ្ឋារចនាសម្ព័ន្ធរូបសាស្ត្រ និងសង្គម ដោយនិរន្តរភាព | - កម្មវិធីជាតិសំណង់សាធារណៈ ដោយប្រើកម្លាំងពលកម្មអតិកម្ម<br>- គម្រោងការស្បៀងពលកម្ម និងសាច់ប្រាក់ពលកម្ម |

| | | |
|---|---|---|
| បង្កើនការថែទាំសុខភាព ដែលអាចទទួលយកបានដល់ជនក្រីក្រ និងងាយរងគ្រោះ (គអសក ៤, ៥, ៦) | ៤. ជនក្រីក្រ និងងាយរងគ្រោះ ទទួលបានប្រកបដោយប្រសិទ្ធិភាព នូវការថែរក្សាសុខភាពដែលមានគុណភាពអាចទទួលយកបាន និងការគាំពារហិរញ្ញវត្ថុ ក្នុងពេលមានជម្ងឺ | - ការពង្រីកមូលនិធិសមធម៌សុខភាព(សម្រាប់ជនក្រីក្រ) និងការធានារ៉ាប់រងសុខភាពនៅសហគមន៍ (សម្រាប់ជននៅក្បែរបន្ទាត់នៃភាពក្រីក្រ) |
| បង្កើនការគាំពារសង្គម សម្រាប់ជនងាយរងគ្រោះពិសេសមួយចំនួន (គអសក ១, ៦, ៩) | ៥. ជនងាយរងគ្រោះពិសេស ទទួលបានការទ្រទ្រង់ជាប្រាក់ចំណូល សម្ភារៈ និងការគាំទ្រចិត្តសាស្ត្រសង្គម និងការថែទាំសង្គមគ្រប់គ្រាន់ | - សេវាកម្មសុខមាលភាពសង្គម សម្រាប់ជនងាយរងគ្រោះពិសេស<br>- ការឧបត្ថម្ភសង្គម និងប្រាក់សោធននិវត្តសង្គម សម្រាប់ជនចាស់ជរា និងប្រជាជនដែលមានជម្ងឺរ៉ាំរ៉ៃ និងជនពិការ |

## កិច្ចការសម្របសម្រួល

១៥. យុទ្ធសាស្ត្រគាំពារសង្គម ត្រូវបានរៀបចំឡើងដោយសម្របជាមួយសកម្មភាពអាទិភាព ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ។ ឯកសារនេះ ក៏បំពេញបន្ថែមទៅលើឯកសារយុទ្ធសាស្ត្រ និងផែនការនៃវិស័យដទៃទៀត ដែលមានជាប់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការគាំពារសង្គម។ ផែនការនិងយុទ្ធសាស្ត្រទាំងនេះ ជាច្រើនក៏ដូចជាសកម្មភាពដែលពាក់ព័ន្ធដទៃទៀត គឺជាការងារបំពេញបន្ថែមគ្នាទៅវិញទៅមក នៃការកសាងប្រព័ន្ធគាំពារសង្គមដ៏ទូលំទូលាយ មានលក្ខណៈចម្រុះ និងស៊ីសង្វាក់គ្នា សម្រាប់ជួយដល់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។

១៦. ការអនុវត្តអន្តរាគមន៍គាំពារសង្គម ជាភារកិច្ច និងជាការទទួលខុសត្រូវនៃក្រសួងជំនាញ និងស្ថាប័នអជ្ញាធរមូលដ្ឋានគ្រប់ថ្នាក់ ។ **យុទ្ធសាស្ត្រគាំពារសង្គម** មានគោលបំណងក្នុងការបំពេញបន្ថែមនូវកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងជំនាញ ក្នុងការសម្រេចឱ្យបាននូវគោលដៅ តាមវិស័យជំនាញ ក្នុងវិធានការណ៍គាំពារសង្គម តាមរយៈការផ្តល់នូវក្របខណ្ឌនៃការអនុវត្តប្រកបដោយនិរន្តភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិ។ កម្មវិធីភាគច្រើននៃយុទ្ធសាស្ត្រគាំពារសង្គម មានចរិតជាអន្តរវិស័យ និងទាមទារនូវការសម្របសម្រួលអន្តរក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល ដើម្បីជៀសវាងការត្រួតជាន់គ្នាជាលក្ខណៈវិស័យ និងតំបន់ភូមិសាស្ត្រ ក៏ដូចជាដើម្បីធ្វើសុខដុមនីយកម្មលើការអនុវត្តនិតិវិធី និងដើម្បីសម្របសម្រួលលើការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព និងដោយសក្តិសិទ្ធ នូវធនធានដែលទទួលបានពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៍។ ប្រការនេះក៏បាននាំមកតម្រូវការនៃ ការប្រាស្រ័យទាក់ទងដោយសកម្ម ជាមួយដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។

១៧. ដើម្បីអនុវត្ត យុទ្ធសាស្ត្រគាំពារសង្គម រាជរដ្ឋាភិបាលកម្ពុជានឹងពិចារណាថែមទៀតនូវយន្តការ និង រចនាសម្ព័ន្ធសមស្រប សម្រាប់ការសម្របសម្រួលលើការគាំពារសង្គម ដើម្បីផ្តល់ការគាំទ្រគោលនយោបាយ ការត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង និងការកសាងសមត្ថភាព។ តាមរយៈការ ទ្រទ្រង់ទាំងឡាយចាំបាច់ចំពោះក្រសួងស្ថាប័នជាភ្នាក់ងារអនុវត្ត រាជរដ្ឋាភិបាលមានគោលបំណងក្នុងការ :

- ជៀសវាងការត្រួតជាន់គ្នា ឬចន្លោះប្រហោងតំបន់ភូមិសាស្ត្រ ក្នុងការផ្តល់ការគាំពារសង្គម
- ជៀសវាងការត្រួតជាន់គ្នា ឬចន្លោះប្រហោងក្នុងការកំណត់គោលដៅការគ្របដណ្តប់នៃអ្នក ទទួលផល
- ធ្វើសុខដុមនីយកម្មលើនីតិវិធីនៃការអនុវត្ត
- ពង្រឹងសមត្ថភាពនៃក្រសួង ស្ថាប័ន ក្នុងការអនុវត្តការអន្តរាគមន៍ការគាំពារសង្គម
- គាំទ្រដល់រចនាសម្ព័ន្ធអជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាខេត្ត ស្រុក ឃុំ) ក្នុងការចូលរួមពាក់ព័ន្ធនឹង ការគាំពារសង្គម
- ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃលើភាពងាយរងគ្រោះ
- ពង្រឹងដល់ការត្រួតពិនិត្យ និងវាយតម្លៃអន្តរាគមន៍គាំពារសង្គម
- ពង្រឹងដល់ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងសម្រាប់ការគាំពារសង្គម
- ពង្រឹងដល់ការចូលរួមនៃអ្នកទទួលផល (ក្នុងយន្តការលើកគម្រោង ត្រួតពិនិត្យឡើងវិញ និងការ ឆ្លើយតប)
- សម្របសម្រួលការប្រើប្រាស់ធនធានដែលមាន

## ការជ្រើសរើស និងការកំណត់គោលដៅ

១៨. យន្តការកំណត់គោលដៅដ៏សមស្របមួយ ជាកត្តាចាំបាច់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធិភាព លើការចំណាយ និងភាពសក្តិសិទ្ធ នៃ **យុទ្ធសាស្ត្រគាំពារសង្គម** ។ អភិក្រមមួយចំនួនក្នុងការជ្រើសរើសអ្នក ទទួលផលសម្រាប់អន្តរាគមន៍គាំពារសង្គម នឹងត្រូវប្រើប្រាស់ រួមមានការកំណត់គោលដៅដោយស្ម័គ្រចិត្ត ការកំណត់គោលដៅដោយតំបន់ភូមិសាស្ត្រ និងការកំណត់ គោលដៅតាមគ្រួសារ។

១៩. ការកំណត់គោលដៅតាមគ្រួសារ នឹងត្រូវមានមូលដ្ឋានជាបឋមទៅលើកម្មវិធីអត្តសញ្ញាណកម្មជន ក្រីក្រ ដែលរៀបចំដោយក្រសួងផែនការ ដើម្បីសម្រេចអោយបាននូវការធ្វើសុខដុមនីយកម្ម និងឯកភាព នៃ ការកំណត់លក្ខខណ្ឌជំរើសគោលដៅជនក្រីក្រ។ រាជរដ្ឋាភិបាលកម្ពុជា មានទិសដៅក្នុងការប្រើប្រាស់ កម្មវិធី

អត្តសញ្ញាណកម្មជនក្រីក្រ ជាវិធីសាស្ត្រកំណត់គោលដៅបឋម សម្រាប់គ្រប់គម្រោងការគាំពារសង្គម ទាំងអស់ ព្រមជាមួយគ្នានេះក៏អនុញ្ញាតឱ្យមានការប្រើប្រាស់នូវវិធីសាស្ត្របំពេញបន្ថែមនានា ក្នុងករណីចាំបាច់។

# កិច្ចការអាទិភាពចំពោះមុខ

២០. ការកសាងឡើងនូវសមត្ថភាពស្ថាប័ន នៅក្នុងយន្តការសម្របសម្រួលថ្នាក់កណ្តាល និងស្ថាប័នពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងជាអាទិភាពចម្បងសម្រាប់អនាគតបន្ទាប់ទៅនេះ គឺជាការរៀបចំស្ថាប័ន និងការសម្របសម្រួលដោយមានតួនាទីជាក់លាក់ ព្រមទាំងរចនាសម្ព័ន្ធត្រួតពិនិត្យសម្រាប់ការបន្ត **យុទ្ធសាស្ត្រគាំពារសង្គម** ក្នុងដំណាក់កាលមធ្យម និងវែង។

២១. កម្មវិធីគាំពារសង្គមដែលកំពុងមានសកម្មភាព និងការសាកល្បងអនុវត្តសកម្មភាពសង្គមកិច្ចថ្មីៗ នឹងកាន់តែមានសុខុដុមនីយភាព និងត្រូវពិចារណាវាយតម្លៃធ្វើសមាហរណកម្មទៅក្នុង កម្មវិធីកម្រិតជាតិ កាន់តែធំជាងមុន ក្នុងការអនុវត្ត **យុទ្ធសាស្ត្រគាំពារសង្គម** ក្នុងដំណាក់កាលមធ្យម និងវែង ដើម្បីនាំយកមកនូវគម្រោងការផ្សេងៗមួយចំនួនទៀត ឱ្យស្ថិតនៅក្រោមកម្មវិធីដែលមានលក្ខណៈចម្រុះមួយ យ៉ាងហោចណាស់ ក្នុងវាល់កម្មវត្ថុនីមួយៗ។

២២. ការធ្វើនិទស្សន៍លើការចំណាយ មានលក្ខណៈគ្រាន់តែជាសូចនាករប៉ុណ្ណោះ ហើយហិរញ្ញប្បទានពិតប្រាកដនឹងត្រូវកំណត់ឡើងទៅតាមការវាយតម្លៃ និងវិភាគជាបន្តទៀត។ ភាគច្រើននៃសកម្មភាពអាទិភាព ត្រូវបានធានាដោយថវិកាមួយចំនួនរួចជាស្រេចហើយតាមរយៈថវិកាជាតិ និងជាមួយនឹងការទ្រទ្រង់នៃដៃគូអភិវឌ្ឍន៍ ។ សកម្មភាពអាទីភាពមួយចំនួនទៀត ជាអន្តរាគមន៍ថ្មី។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១. ហានិភ័យ វិបត្តិ កត្តាកំណត់នៃភាពងាយរងគ្រោះ និងក្រុមងាយរងគ្រោះ

ឧបសម្ព័ន្ធទី ២. ចន្លោះប្រហោង និងបញ្ហាប្រឈមនៅក្នុងអន្តរាគមន៍ដែលមានស្រាប់

ឧបសម្ព័ន្ធទី ៣. សកម្មភាពជាអាទិភាពក្នុងដំណាក់កាលខ្លីរបស់ យជគស និងការប៉ាន់ស្មានចំណាយ

## ឧបសម្ព័ន្ធទី ១. ហានិភ័យ វិបត្តិ កត្តាកំណត់នៃភាពងាយរងគ្រោះ និងក្រុមងាយរងគ្រោះ[1]

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | កត្តាកំណត់នៃភាពងាយរងគ្រោះ | លទ្ធផល | ក្រុមងាយរងគ្រោះបំផុត |
|---|---|---|---|---|
| ១. ស្ថានភាពគ្រោះអាសន្ន និងកល្លិយុគ | វិបត្តិសេដ្ឋកិច្ច (ការកើនឡើងនៃតម្លៃ និងការធ្លាក់ចុះនៃវិស័យសេដ្ឋកិច្ច) | - មានកាលានុវត្តភាពទាបក្នុងការបង្កើតប្រាក់ចំណូល<br>- ប្រមូលផ្តុំនៅក្នុងពីការងារដែលអសុវត្ថិភាព និងមិនទៀងទាត់<br>- ការកាត់បន្ថយចំនួនការងារក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ច<br>- ការកាត់បន្ថយអំណាចនៃការទិញរបស់ប្រាក់បៀវត្ស | - កំណើនការបាត់បង់ និងកង្វះការងារ<br>- កំណើនការងារដែលមានប្រាក់បំណាច់ឆ្នាំទាប អសុវត្ថិភាព និងមានគ្រោះថ្នាក់<br>- ការផ្ញើរប្រាក់មានតិចតួច | - ជនក្រីក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រទាំងអស់ |
| | គ្រោះមហន្តរាយ ធម្មជាតិ អាកាសធាតុ និងបរិស្ថាន (ទឹកជំនន់ គ្រោះរាំងស្ងួត) | - ពឹងផ្អែកលើការដាំដំណាំ និងការចិញ្ចឹមសត្វដើម្បីផលិតអាហារ និងរកប្រាក់ចំណូលត្រឹមតែចិញ្ចឹមក្រពះ<br>- ពឹងផ្អែកលើធនធានធម្មជាតិទូទៅ (ដែលជាញឹកញាប់មានភាពរេចរឹល ការប្រើប្រាស់ហួសកម្រិត និងមានវិវាទ) ដើម្បីចិញ្ចឹមជីវិត<br>- រស់នៅតាមតំបន់ដាច់ស្រយាល និងទទួលរងផលប៉ះពាល់ពីកង្វះហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍<br>- មូលដ្ឋានសន្សំប្រាក់ និងទ្រព្យសម្បត្តិតិចតួច ដើម្បីដោះស្រាយតម្រូវការបន្ទាន់ | - ការបំផ្លិចបំផ្លាញ ឬការសឹករេចរឹលទ្រព្យសម្បត្តិ និងប្រភពធម្មជាតិ<br>- កំណើនការបាត់បង់ និងកង្វះការងារ<br>- ការកើនឡើងនូវឧប្បត្តិហេតុ និងភាពធ្ងន់ ធ្ងរនៃអសន្តិសុខស្បៀង<br>- ប្រាក់ចំណូលទាប | - ជនក្រីក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រទាំងអស់<br>- ប្រជាជនរស់នៅតាមតំបន់មានទឹកជំនន់ និងភាពរាំងស្ងួតញឹកញាប់ |
| ២. ឧបសគ្គក្នុងការអភិវឌ្ឍន៍មនុស្ស | ភាពអន់ថយសុខភាព និងអាហារូបត្ថម្ភនៃមាតា និងទារក | - មានប្រាក់ចំណូលទាប និងរងគ្រោះដោយសារអសន្តិសុខស្បៀង<br>- មានលទ្ធភាពតិចតួច ក្នុងការទទួលបានការថែទាំសុខភាពមាតា ទារក និងកុមារដែលមានគុណភាព | - កំណើនឧប្បត្តិហេតុ និងភាពធ្ងន់ធ្ងរនៃកង្វះអាហារូបត្ថម្ភ ក្រិន និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតីមានកម្រិតទាប | - ក្មេងស្រី និងស្ត្រីក្នុងវ័យបន្តពូជ<br>- ស្ត្រីមានផ្ទៃពោះ |

[1] ហានិភ័យ ជាប្រភពនៃគ្រោះថ្នាក់ ឬជាលទ្ធភាពដែលនាំឱ្យមានការខូចបង់ ឬការមិនអាចសម្រេចគោលដៅ។ នៅពេលដែលហានិភ័យកើតឡើងវានឹងបង្កឱ្យកើតមានជាវិបត្តិ។ ភាពងាយរងគ្រោះរបស់បុគ្គល ឬគ្រួសារ ចំពោះហានិភ័យ ឬវិបត្តិ អាស្រ័យលើកម្រិតនៃការប្រឈម និងសមត្ថភាពក្នុងការដោះស្រាយវិបត្តិ។ ប្រជាជនដែលរស់នៅក្រោម ឬក្បែរបន្ទាត់នៃភាពក្រីក្រ មានភាពងាយរងគ្រោះខ្ពស់ដោយសារលទ្ធផលអវិជ្ជមាននៃវិបត្តិនេះ។ ខណៈពេលដែលជនក្រីក្រ និងជនដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ មានភាពងាយរងគ្រោះ ដោយសារវិបត្តិនានា ក្រុមនៃប្រជាជនមួយចំនួនកាន់តែងាយរងគ្រោះដោយវិបត្តិទាំងនេះ។

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | កត្តាកំណត់នៃភាពងាយរងគ្រោះ | លទ្ធផល | ក្រុមងាយរងគ្រោះបំផុត |
|---|---|---|---|---|
| | | | - អត្រាមរណៈមាតាខ្ពស់<br>- អត្រាមរណៈទារកខ្ពស់ | - កុមារតូច (០-៥) |
| | លទ្ធភាព ទទួលបានការអប់រំដែលមានគុណភាព នៅមានកម្រិត | - កើតឡើងដោយសារកត្តាអូសទាញ ដើម្បីធ្វើការតាមមូលដ្ឋាន ជួយការងារក្នុងគ្រួសារ ឬចេញទៅរកការងារខាងក្រៅ ដោយសារផ្តល់ប្រាក់ចំណូលទាប និងអសន្តិសុខស្បៀងក្នុងគ្រួសារ<br>- មានលទ្ធភាពទទួលបាសេវាកម្មអប់រំ ដែលមានគុណភាពមានកម្រិត | - អត្រាបោះបង់ការសិក្សាខ្ពស់ និងទទួលបានជំនាញមានកម្រិតទាប<br>- កំណើននៃឧប្បត្តិហេតុពលកម្មកុមារ (ពីអាយុ ៦ឆ្នាំ ដល់ ១៥ឆ្នាំ)<br>- កំណើនការបាត់បង់ និងកង្វះការងារ<br>- កំណើនការងារដែលមានប្រាក់បំណាច់ឆ្នាំទាប អសុវត្ថិភាព និងមានគ្រោះថ្នាក់<br>- កំណើនគ្រោះថ្នាក់ ឬទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (១៥-១៧) | - អាយុចូលរៀន (៦-១៤) |
| | លទ្ធភាពទទួលបាន កម្មវិធីផ្តល់ឱកាសថ្មី ដែលមានគុណភាព នៅមានកម្រិត | - មានមូលហេតុកត្តាអូសទាញឱ្យស្ថិតក្នុងការងារដែលគ្រោះថ្នាក់ និងប្រាក់កម្រៃទាប<br>- មានលទ្ធភាពទទួលបានតិចតួច នូវសេវាកម្មបណ្តុះបណ្តាលដែលមានគុណភាព | | - យុវជន (១៥-២៤) |
| ៣. ភាពគ្មានការងារធ្វើ និងកាលានុវត្តភាពនៃការចិញ្ចឹមជីវិតតាមរដូវកាល | កង្វះអាហាររូបត្ថម្ភនិងអាហារូបត្ថម្ភកម្រិតទាប | - ពឹងផ្អែកលើការដាំដំណាំ និងការចិញ្ចឹមសត្វដើម្បីផលិតអាហារ និងរកប្រាក់ចំណូលត្រឹមតែចិញ្ចឹមក្រពះ<br>- គ្មានការងារជាប់លាប់ ដើម្បីរកប្រាក់ ចំណូលបន្ថែមក្រៅពីការធ្វើកសិកម្ម<br>- ពឹងផ្អែកលើធនធានធម្មជាតិទូទៅ (ដែលជាញឹកញាប់មានភាពរេចរឹល ការប្រើប្រាស់ហួសកម្រិត និងមានវិវាទ) ដើម្បីចិញ្ចឹមជីវិត<br>- មានអ្នកស្ថិតក្នុងបន្ទុកគ្រួសារច្រើន<br>- អាចជាប្រជាជនដែលគ្មានដីជាកម្មសិទ្ធិ ឬមានលទ្ធភាពទាបក្នុងការទទួលបានដី និងមានដីកាន់កាប់តូច | - អត្រាមរណៈមាតាខ្ពស់<br>- កំណើនឧប្បត្តិហេតុ និងភាពធ្ងន់ធ្ងរនៃកង្វះអាហារូបត្ថម្ភ ក្រិន និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតីមានកម្រិតទាប<br>- កំណើននៃការធ្លាក់ចុះផ្នែកសុខភាព<br>- ការធ្លាក់ចុះនៃសមត្ថភាពសិក្សា ឬការងារប្រកបដោយផលិតភាព | - ជនក្រីក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រទាំងអស់<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥)<br>- គ្រួសារដែលមានសមាជិកច្រើនដែលពុំអាចធ្វើការ<br>- គ្មានដីជាកម្មសិទ្ធិ និងគ្មានដីធ្វើកសិកម្ម |

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | កត្តាកំណត់នៃភាពងាយរងគ្រោះ | លទ្ធផល | ក្រុមងាយរងគ្រោះបំផុត |
|---|---|---|---|---|
| ៤. វិបត្តិផ្នែកសុខភាព | សុខភាពមិនល្អ របួស ជម្ងឺ មរណភាព ជម្ងឺរាតត្បាត | - លទ្ធភាពទាបក្នុងការទទួលបានទឹកស្អាត និងអនាម័យ<br>- រស់នៅក្នុងផ្ទះមានស្ថានភាពក្រខ្សត់<br>- មានមូលដ្ឋានសន្សំប្រាក់ និងទ្រព្យសម្បត្តិទាប ពិសេសត្រូវចំណាយថវិកាអស់ពីខ្លួនដើម្បីព្យាបាលជម្ងឺ<br>- មានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាកម្មគាំពារ និងថែទាំសុខភាព ដែលមានគុណភាព<br>ធ្វើការងារប្រើកម្លាំងកាយដែលប្រកបដោយគ្រោះថ្នាក់ និងការរងរបួសផ្សេងៗ | - អត្រាមរណមាតាខ្ពស់<br>- អត្រាមរណទារកខ្ពស់<br>- កំណើនឧប្បត្តិហេតុ និងភាពធ្ងន់ធ្ងរនៃកង្វះអាហារូបត្ថម្ភ ក្រិន និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតីមានកម្រិតទាប<br>- ការបាត់បង់ទ្រព្យសម្បត្តិ និងកំណើននៃការខ្ចីបុល | - ជនក្រីក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រទាំងអស់<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥)<br>- ចាស់ជរា<br>- ជនពិការ |
| ៥. ក្រុមងាយរងគ្រោះពិសេស | អសមត្ថភាពការងារ កង្វះការយកចិត្តទុកដាក់ពីសង្គម | - មានលទ្ធភាពតិចតួចក្នុងការទទួលបានការងារបង្កើតប្រាក់ចំណូល<br>- ខ្វះការយកចិត្តទុកដាក់ពីសង្គម មានលទ្ធភាពទាបក្នុងការទទួលបានសេវាកម្ម និងការបដិសេដពីកាលានុវត្តភាពផ្សេងៗ | - កំណើនអសន្តិសុខប្រាក់ចំណូល និងស្បៀង<br>- កំណើនលទ្ធភាពដែលអាចក្លាយ ជាជនរងគ្រោះនៃអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានលើពលកម្ម និងផ្លូវភេទ | - ជនចាស់ជរា<br>- ជនពិការ<br>- ជនដែលមានជម្ងឺរ៉ាំរ៉ៃ<br>- ជនជាតិដើមភាគតិច<br>- ក្មេងកំព្រា<br>- ពលករកុមារ<br>- ជនរងគ្រោះ ដោយអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន<br>- ជនចូលនិវត្តន៍<br>- គ្រួសារចំណាកស្រុក |

## ឧបសម្ព័ន្ធទី ២. ចន្លោះប្រហោង និងបញ្ហាប្រឈមនៅក្នុងអន្តរាគមន៍ដែលមានស្រាប់

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | ក្រុមងាយរងគ្រោះបំផុត | ខឿនភាពមគនល់បច្ចុប្បន្ន ក្នុងការឆ្លើយតប | ចន្លោះប្រហោង និងការប្រឈមក្នុងការឆ្លើយតប |
|---|---|---|---|---|
| ១. ស្ថានភាពគ្រោះអាសន្ន និងកល្លិយុគ | វិបត្តិសេដ្ឋកិច្ច | - ជនក្រីក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រទាំងអស់ | - កម្មវិធីសំណង់សាធារណៈ បាបបង្ហាញថាមានប្រសិទ្ធិភាព និងជាឧបករណ៍បណ្ដាញសុវត្ថិភាពសង្គមដែលអាចពង្រីកទំហំបានឆាប់ ក្នុងពេលមានកល្លិយុគ និងគ្រោះធម្មជាតិ | - ការគ្របដណ្ដប់ និងការសម្របសម្រួលលើកម្មវិធីសំណង់សាធារណៈដែលមានស្រាប់ នៅមានកម្រិតទាប |
| | គ្រោះមហន្តរាយ ធម្មជាតិ អាកាសធាតុ និងបរិស្ថាន | - ជនក្រីក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រទាំងអស់<br>- ប្រជាជនរស់នៅតាមតំបន់មានទឹកជំនន់ និងភាពរាំងស្ងួតញឹកញាប់ | | |
| ២. ឧបសគ្គក្នុងការអភិវឌ្ឍន៍មនុស្ស | ភាពអន់ថយសុខភាព និងអាហារូបត្ថម្ភនៃមាតា និងទារក | - ក្មេងស្រី និងស្ត្រីក្នុងវ័យបន្តពូជ<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥) | - កម្មវិធីអាហារូបត្ថម្ភមាតា និងកុមារ មួយចំនួនកំពុងមានដំណើរការ<br>- ការបំបៅកូនដោយទឹកដោះកំពុងតែប្រសើរជាងមុន | - ការផ្ដល់សេវាអាហារូបត្ថម្ភមាតា និងកុមារ នៅមានកម្រិត ហើយមានគុណភាពទាប<br>- ការគ្រប់ដណ្ដប់នៃសេវាកម្មនេះ ពុំបានមានសម្រាប់គ្រប់គ្នា<br>- កត្តាដែលបណ្ដាលមកពីផ្នែកតម្រូវការផ្សេងទៀត (ការបរិភោគ ការផ្ដល់ចំណី និងការថែទាំ) ពុំបានលើកយកមកពិនិត្យឱ្យបានដិតដល់ |
| | លទ្ធភាព ទទួលបានការអប់រំដែលមានគុណភាព នៅមានកម្រិត | - អាយុចូលរៀន (៦-១៤) | - កម្មវិធីអាហារូបករណ៍ និងការផ្ដល់ស្បៀងនៅសាលា បង្កើនការចូលរៀនក្នុងថ្នាក់ | - គុណភាពនៃការអប់រំនៅមានកម្រិត<br>- ការគ្របដណ្ដប់នៃសេវាកម្មអប់រំ មានភាពប្រែប្រួលតាមតំបន់ តំបន់គ្របដណ្ដប់នៃកម្មវិធីអាហារូបករណ៍ និងការផ្ដល់ស្បៀងនៅសាលា ពុំបានឈានដល់គ្រប់តំបន់ក្រីក្រ |
| | លទ្ធភាពទទួលបាន កម្មវិធី | - យុវជន (១៥-២៤) | - ការបង្កើតកម្មវិធីវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ | - គុណភាពនៃវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅមានកម្រិត |

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | ក្រុមងាយរងគ្រោះបំផុត | វឌ្ឍនភាពមកទល់បច្ចុប្បន្ន ក្នុងការឆ្លើយតប | ចន្លោះប្រហោង និងការប្រឈមក្នុងការឆ្លើយតប |
|---|---|---|---|---|
| | ផ្ដល់ឱកាសថ្មី ដែលមានគុណភាព នៅមានកម្រិត | | - កម្មវិធីផ្ដល់លទ្ធភាពទទួលបានឱកាសសិក្សាថ្មីមួយចំនួន កំពុងមានដំណើរការ | - កម្មវិធីផ្ដល់លទ្ធភាពទទួលបានឱកាសសិក្សាថ្មី នៅមានកម្រិតអប្បរមា<br>- កង្វះទំនាក់ទំនងរវាងប្រភេទវគ្គបណ្ដុះបណ្ដាល និងតម្រូវការសិក្ខាកាម<br>- ពុំមានប្រព័ន្ធផ្ដល់វិញ្ញាបនបត្រ ឬការទទួលស្គាល់គុណភាព សម្រាប់វិស័យឯកជន |
| ៣. ភាពគ្មានការងារធ្វើ និងកាលានុវត្តភាពនៃការចិញ្ចឹមជីវិតតាម រដូវកាល | កង្វះអាហាររូបត្ថម្ភនិងអាហារូបត្ថម្ភកម្រិតទាប | - ជនក្រីក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រទាំងអស់<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥)<br>- គ្រួសារដែលមានសមាជិកច្រើនដែលពុំអាចធ្វើការ<br>- គ្មានដីជាកម្មសិទ្ធិ និងមានដីតូច | - កម្មវិធីចែកស្បៀងដោយមានគោលដៅមួយចំនួន កំពុងមានដំណើរការ<br>- កម្មវិធីផ្ដល់ស្បៀងនៅសាលា<br>- កម្មវិធីសំណង់សាធារណៈ ផ្ដល់នូវជំនួយមួយចំនួនក្នុងរដូវខ្វះស្បៀង និងកល្លិយុគ | - ការគ្របដណ្ដប់ និងការសម្របសម្រួលលើកម្មវិធីសំណង់សាធារណៈដែលមានស្រាប់ នៅមានកម្រិតទាប<br>- ការផ្ដល់ហិរញ្ញប្បទាន និងជំនួយ ពុំស្ថិតស្ថេរ |
| ៤. វិបត្តិផ្នែកសុខភាព | សុខភាពមិនល្អ របួស ជម្ងឺ មរណភាព ជម្ងឺរាតត្បាត | - ជនក្រីក្រ និងក្បែរបន្ទាត់នៃភាពក្រីក្រទាំងអស់<br>- ស្ត្រីមានផ្ទៃពោះ<br>- កុមារតូច (០-៥)<br>- ចាស់ជរា<br>- ជនពិការ | - មូលនិធិសមធម៌សុខភាព ផ្ដល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដល់ជនក្រីក្រ នៅតំបន់មួយចំនួន | - គុណភាពសេវាកម្មថែទាំសុខភាព នៅមានកម្រិតទាប<br>- ការគ្របដណ្ដប់ និងលទ្ធភាពទទួលបានមូលនិធិសមធម៌សុខភាព ពុំបានសម្រាប់ប្រជាជនគ្រប់គ្នា |

| ហានិភ័យ និងវិបត្តិសំខាន់ៗ | | ក្រុមងាយរងគ្រោះបំផុត | ស្ថានភាពមកទល់បច្ចុប្បន្ន ក្នុងការឆ្លើយតប | ចន្លោះប្រហោង និងការប្រឈមក្នុងការឆ្លើយតប |
|---|---|---|---|---|
| ៥. ក្រុមងាយរងគ្រោះពិសេស | អសមត្ថភាពការងារ កង្វះការយកចិត្តទុកដាក់ពីសង្គម | - ជនចាស់ជរា<br>- ជនពិការ<br>- ជនដែលមានជម្ងឺរ៉ាំរ៉ៃ<br>- ជនជាតិដើមភាគតិច<br>- ក្មេងកំព្រា<br>- ពលករកុមារ<br>- ជនរងគ្រោះ ដោយអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន<br>- ជនចូលនិវត្តន៍<br>- គ្រួសារចំណាកស្រុក | - របបសោធននិវត្តសម្រាប់មន្ត្រីរាជការ បេឡាជាតិសន្តិសុខសង្គមសម្រាប់និយោជិកវិស័យឯកជន<br>- ជំនួយពីស្ថាប័នមួយចំនួនដល់ជនពិការ<br>- ជំនួយមួយចំនួនដល់ជនជាតិដើមភាគតិច | - គ្មានរបបសោធននិវត្តដល់ជនក្រីក្រ<br>- ជំនួយសម្រាប់ជនចាស់ជរា មានកម្រិតតូចបំផុត<br>- ជំនួយសម្រាប់ក្រុមជនងាយរងគ្រោះពិសេស នៅមានកម្រិតតិចតួច |

## ឧបសម្ព័ន្ធទី ៣. សកម្មភាពជាអាទិភាពក្នុងដំណាក់កាលខ្លីរបស់ យជគស និងការប៉ាន់ស្មានចំណាយ

| កម្មវិធី និងសកម្មភាពអាទិភាពរយៈពេលខ្លី | | ស្ថាប័នអនុវត្ត | ចំនួនប៉ាន់ស្មាននៃគម្រិត និងអ្នកទទួលផល | ស្ថានភាពហិរញ្ញប្បទាន |
|---|---|---|---|---|
| **សកម្មភាពនាំមុខជាអាទិភាព** | | | | |
| 0.១ | ផ្សព្វផ្សាយ យជគស នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | កកជ | | កំពុងរក |
| 0.២ | កំណត់តួនាទី និងមុខងារ និងបង្កើតរចនាសម្ព័ន្ធសម្របសម្រួលរវាងស្ថាប័នផ្តល់ជំនួយ និងស្ថាប័នរាជរដ្ឋាភិបាល | កកជ | | កំពុងរក |
| 0.៣ | គណនាការចំណាយរយៈពេលមធ្យម និងរយៈពេលវែងរបស់ យជគស និងកំណត់កាលានុវត្តភាព ក្នុងការប្រមូលផ្តុំនិងរៀបចំហិរញ្ញប្បទានរួមគ្នាសម្រាប់ការគាំពារសង្គម | កកជ | | កំពុងរក |
| 0.៤ | វាយតម្លៃតម្រូវការកសាងសមត្ថភាព និងបង្កើតផែនការអភិវឌ្ឍន៍ធនធានមនុស្ស | កកជ | | កំពុងរក |
| 0.៥ | កសាងសមត្ថភាព សម្រាប់ការរៀបចំការគាំពារសង្គម ការសម្របសម្រួល និងការត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ជាតិ (កកជ និងក្រសួងពាក់ព័ន្ធ) (ក្រុមគ្រូបង្គោល) | កកជ | | កំពុងរក |
| 0.៦ | កសាងសមត្ថភាព សម្រាប់ការសម្របសម្រួល និងការត្រួតពិនិត្យលើការគាំពារសង្គម នៅថ្នាក់ក្រោមជាតិ | កកជ | | កំពុងរក |
| 0.៧ | បង្កើត និងថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងគ្រប់គ្រងព័ត៌មាន សម្រាប់ការគាំពារសង្គម ក្នុង កកជ | កកជ | | កំពុងរក |
| 0.៨ | ពង្រីកវិសាលភាព របស់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទៅដល់គ្រួសារនៅតំបន់ជនបទទាំងអស់ និងធ្វើបច្ចុប្បន្នកម្មលើបញ្ជីគ្រួសារក្រីក្រ រាល់ពីរឆ្នាំម្តង | ក្រ.ផែនការ | ២០១០ : ខេត្តចំនួន ១១ ប្រមាណ ១,២ លានគ្រួសារ ក្នុងគម្រោង<br>២០១១-១៣ : ក្នុង ១ឆ្នាំ ចំនួន ១២ខេត្ត ប្រមាណ ១,២លានគ្រួសារ ក្នុងគម្រោង | រកបាន សម្រាប់ឆ្នាំ ២០១០ និង២០១១ |
| 0.៩ | រៀបចំ និងអនុវត្តសាកល្បងប្រព័ន្ធកំណត់គ្រួសារក្រីក្រនៅតំបន់ប្រជុំជន | ក្រ.ផែនការ | | |
| **គោលបំណងទី ១. ឆ្លើយតបតម្រូវការមូលដ្ឋាន ក្នុងស្ថានភាពអាសន្ន និងកល្លិយុគ** | | | | |
| ១.១ | ការចែកស្បៀងដល់ក្រុមគោលដៅ | ក្រ.សេដ្ឋកិច្ច | ADB/EFAP | រកបាន |
| ១.២ | ការចែកសម្ភារៈកសិកម្ម | ក្រ.សេដ្ឋកិច្ច | ADB/EFAP EC/FAO ជំនួយស្បៀង | រកបាន |

| កម្មវិធី និងសកម្មភាពអាទិភាពរយៈពេលខ្លី | | ស្ថាប័នអនុវត្ត | ចំនួនប៉ាន់ស្មាននៃកម្រិត និងអ្នកទទួលផល | ស្ថានភាពហិរញ្ញប្បទាន |
|---|---|---|---|---|
| | | ក្រ.កសិកម្ម | | |
| ១.៣ | ជំនួយសង្គ្រោះបន្ទាន់ | ក្រ.សង្គមកិច្ច | ផ្អែកលើកម្មវិធីការងារ ឆ្នាំ២០០៨-១៣ របស់ក្រ.សង្គមកិច្ច នៅត្រឹមឆ្នាំ២០១៣ អ្នកទទួលផល រួមមានជនរងគ្រោះចំនួន ២៥០,០០០ (៥០,០០០ ក្នុងមួយឆ្នាំ) រួមមាន ជនរងគ្រោះដោយគ្រោះធម្មជាតិ និង ប្រជាជនក្រីក្រជួបប្រទះកង្វះស្បៀង នឹងទទួលបានជំនួយសង្គ្រោះបន្ទាន់។ | រកបាន |
| | ជំនួយសង្គ្រោះបន្ទាន់ - គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | | | |
| **គោលបំណងទី ២. ការកាត់បន្ថយភាពក្រីក្រ និងងាយរងគ្រោះរបស់កុមារ និងមាតា** | | | | |
| ២.១ | បង្កើតកម្មវិធីឧបត្ថម្ភសាច់ប្រាក់ថ្មីមួយ ដើម្បីជួយដល់ប្រជាជនក្រីក្រ ដោយផ្តោតលើកង្វះអាហារូបត្ថម្ភ កុមារ និងមាតា (រៀបចំ និងអនុវត្តសាកល្បង ឆ្នាំ ២០១១-២០១២ អនុវត្ត ៥០% ឆ្នាំ២០១៣) | នឹងកំណត់នៅដំណាក់កាលរៀបចំគម្រោង | ២០១២ : កុមារ/មាតា ចំនួន ៦៤.០០០<br>២០១៣ : កុមារ/មាតាចំនួន ១៦០.០០០<br>កម្រិតផលប្រយោជន៍ : ៦០ដុល្លារ ចំពោះកុមារ ម្នាក់/ឆ្នាំ<br>ចំណាយរដ្ឋបាល ១០% | កំពុងរក |
| ២.២ | ការផ្តល់ស្បៀងដោយមានគោលដៅ សម្រាប់អាហារូបត្ថម្ភមាតា និងកុមារ | ក្រ.សុខាភិបាល | ២០១០ : អ្នកទទួលផល ៥០.៤៦០ នាក់<br>២០១១ : អ្នកទទួលផល ៥០.៤៦០ នាក់<br>២០១២ : អ្នកទទួលផល ៥៥.៥០៦ នាក់<br>២០១២ : អ្នកទទួលផល ៥៥.៥០៦ នាក់ | កំពុងរក |
| ២.៣ | ពង្រីកកម្មវិធីផ្តល់អាហារូបករណ៍ ដល់សិស្សមធ្យមសិក្សា ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកុមារងាយរងគ្រោះដោយសារពលកម្មកុមារ | ក្រ.អប់រំ | សាលាចំនួន ៥២៧ ក្នុងគម្រោង CESSP បច្ចុប្បន្ន X កុមារ ៣០នាក់ ជាមធ្យមក្នុងសាលាមួយ X ៤៥ដុល្លារ = ១៥.៨០០ អាហារូបករណ៍ដែលអាចឱ្យ សម្រាប់ឆ្នាំ ២០១១ (៧១១.៤៥០ ដុល្លារ)<br>លទ្ធភាពសម្រាប់ឆ្នាំ២០១២ និង២០១៣ ដើម្បីអនុវត្តដល់សាលាជាច្រើនទៀត | បានផ្តល់ហិរញ្ញប្បទានដោយថវិកាក្រ.អប់រំ |
| ២.៣ | ពង្រីកកម្មវិធីផ្តល់អាហារូបករណ៍ ដល់សិស្សបឋមសិក្សា ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកុមារងាយរងគ្រោះដោយសារពលកម្មកុមារ | ក្រ.អប់រំ | FTI : អនុវត្តសាកល្បង ចុងឆ្នាំ២០១២<br>១០,៤៤២ អាហារូបករណ៍ ឆ្នាំ២០១១<br>៦,៨១៤ អាហារូបករណ៍ ឆ្នាំ២០១២ ដោយមាន ២០ដុល្លារ/សិស្សម្នាក់ ក្នុងខេត្តចំនួន ៣ | រកបាន |

| កម្មវិធី និងសកម្មភាពអាទិភាពរយៈពេលខ្លី | | ស្ថាប័នអនុវត្ត | ចំនួនប៉ាន់ស្មាននៃគម្រោង និងអ្នកទទួលផល | ស្ថានភាពហិរញ្ញប្បទាន |
|---|---|---|---|---|
| | | | ការវាយតម្លៃផលប៉ះពាល់ អាចធ្វើក្នុងឆ្នាំ ២០១៣ | |
| ២.៤ | (ពង្រីក) កម្មវិធីផ្តល់ស្បៀងនៅសាលា | ក្រ.អប់រំ | ២០១០ កុមារចំនួន ៤៥៤.១០០ នាក់<br>២០១១ កុមារចំនួន ៥៦៤.៦៦០ នាក់<br>២០១២ កុមារចំនួន ៦២១.១២៦ នាក់<br>២០១៣ កុមារចំនួន ៦២១.១២៦ នាក់<br>(ថ្នាក់ទី ១-៦ អាហារមួយពេល/ថ្ងៃ) | កំពុងរក |
| ២.៥ | (ពង្រីក) កម្មវិធីផ្តល់អាហារូបករណ៍ជាស្បៀង (របបស្បៀងយកមកផ្ទះ) | ក្រ.អប់រំ | ២០១០ អ្នកទទួលផលចំនួន ៨៩.៦៩៦<br>២០១១ អ្នកទទួលផលចំនួន ៩២.៤០០<br>២០១២ អ្នកទទួលផលចំនួន ១៨៤.៨០០<br>២០១៣ អ្នកទទួលផលចំនួន ១៨៤.៨០០<br>(អង្ករ ១៥គីឡូ សណ្តែក ២គីឡូ ប្រេងឆា ១គីឡូ ប្រចាំខែ ភាគច្រើនផ្តល់ឱ្យសិស្សជាកុមារី រៀនថ្នាក់ទី២-៦ សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ) | កំពុងរក |
| ២.៦ | គាំទ្រដល់ការអនុវត្ត ផែនការជាតិនៃសកម្មភាព លុបបំបាត់ពលកម្មកុមារ | ក្រ.ការងារ | ១២.០០០ ត្រឹមឆ្នាំ២០១២[២] | រកបាន |
| **គោលបំណងទី ៣. កាត់បន្ថយភាពគ្មានការងារធ្វើ និងផ្តល់កាលានុវត្តភាពជីវភាព** | | | | |
| ៣.១ | បង្កើត និងពង្រីកជាបន្តកម្មវិធីសំណង់សាធារណៈ ថ្នាក់ជាតិចម្រុះមួយ ដើម្បីដោះស្រាយបញ្ហាគ្មានការងារធ្វើតាមរដូវកាល របស់ប្រជាជនក្រីក្រនៅតំបន់ជនបទ និងកសាង ទ្រព្យសម្បត្តិសហគមន៍ ប្រកបដោយនិរន្តរភាព | នឹងកំណត់នៅដំណាក់កាលរៀបចំគម្រោង | អ្នកទទួលផលសម្រាប់ឆ្នាំ ២០១១ មានចំនួន ២០.៧៥០ នាក់<br>អ្នកទទួលផលសម្រាប់ឆ្នាំ ២០១២ មានចំនួន ៤២.០០០ នាក់<br>អ្នកទទួលផលសម្រាប់ឆ្នាំ ២០១៣ មានចំនួន ១០៥.៥០០ នាក់<br>ការងាររយៈពេល ៤០ថ្ងៃ/ឆ្នាំ<br>អត្រាប្រាក់ឈ្នួល ១០.០០០ រៀល<br>ចំណាយមិនមែនជាប្រាក់ឈ្នួល ជាមធ្យម ៣០% | កំពុងរក |

[២] អ្នកទទួលផលខាងលើ នឹងត្រូវកំណត់ជាគោលដៅដោយផ្ទាល់ក្រោមគម្រោងដែលផ្តល់មូលនិធិដោយ ILO។ យ៉ាងណាមិញ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារត្រឹមឆ្នាំ ២០១៦។ ចំពោះការបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនេះ គេបានប៉ាន់ស្មានថា នឹងមានការចូលរួមពីធនាគារពិភពលោក អង្គការ UNICEF អង្គការ ILO (**គម្រោងស្វែងយល់ពីការងារកុមារ**) ដើម្បីស្វែងរកមូលនិធិបន្ថែមចំនួន ៩០ លានដុល្លារអាមេរិក។ ដូច្នេះ សម្រាប់រយៈពេល ៣ឆ្នាំ ២០១១-២០១៣ នឹងត្រូវការថវិកាប្រមាណ ៤៥ លានដុល្លារអាមេរិក ពោលគឺ ១៥ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។

| កម្មវិធី និងសកម្មភាពអាទិភាពរយៈពេលខ្លី | | ស្ថាប័នអនុវត្ត | ចំនួនប៉ាន់ស្មាននៃគម្រិត និងអ្នកទទួលផល | ស្ថានភាពហិរញ្ញប្បទាន |
|---|---|---|---|---|
| ៣.២ | បន្តកម្មវិធីស្បៀងពលកម្ម និងប្រាក់ពលកម្មដែលកំពុងអនុវត្ត<br>ក) គម្រោងកម្មវិធីស្បៀងអាហារពិភពលោក<br>ខ) គម្រោងជំនួយស្បៀងសង្គ្រោះបន្ទាន់ | ក្រ.សេដ្ឋកិច្ច ក្រ.អភិវឌ្ឍន៍ជនបទ | អ្នកទទួលផលសម្រាប់ឆ្នាំ ២០១០ មានចំនួន ១៤២.៩១៥ នាក់<br>អ្នកទទួលផលសម្រាប់ឆ្នាំ ២០១១ មានចំនួន ១៨១.២៤៩ នាក់<br>អ្នកទទួលផលសម្រាប់ឆ្នាំ ២០១២ មានចំនួន ២៥០.០០០ នាក់<br>អ្នកទទួលផលសម្រាប់ឆ្នាំ ២០១៣ មានចំនួន ២៥០.០០០ នាក់ | កំពុងរក |
| **គោលបំណងទី ៤. បង្កើនការថែទាំសុខភាពដែលអាចទទួលយកបានសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ** | | | | |
| ៤.១ | ពង្រឹង សម្របសម្រួល និងពង្រីកវិសាលភាពរបស់មូលនិធិសមធម៌សុខភាព | ក្រ.សុខាភិបាល | | រកបាន ប៉ុន្តែនៅមានចន្លោះប្រហោង |
| ៤.២ | ពង្រីកកម្មវិធីការធានារ៉ាប់រងសុខភាពសហគមន៍មូលដ្ឋាន | ក្រ.សុខាភិបាល | នៅបំណាច់ឆ្នាំ ២០០៩ មានគម្រោងចំនួន ១៣ ដែលមានសមាជិក សរុបចំនួន ១២២.៨២៩ នាក់ | កំពុងរក |
| **គោលបំណងទី ៥. ធ្វើឱ្យប្រសើរឡើងនូវការគាំពារសង្គមសម្រាប់ជនងាយរងគ្រោះពិសេស** | | | | |
| ៥.១ | បង្កើតទស្សនទាន សម្រាប់ដោះស្រាយភាពងាយរងគ្រោះចំពោះមនុស្សចាស់ជរាក្រីក្រ អ្នកមានជម្ងឺរ៉ាំរ៉ៃ និងពិការ | ក្រ.សង្គមកិច្ច | យុទ្ធសាស្ត្ររយៈពេលវែង ក្នុងការលើកកម្ពស់ការគាំពារសង្គម សម្រាប់ប្រជាជនក្រីក្រ ចាស់ជរា ជនពិការ (ឧទាហរណ៍ តាមរយៈការឧបត្ថម្ភសាច់ប្រាក់ ឬសោធនសង្គម) ដែលនឹងរៀបចំ និងព្រមព្រៀងនៅខែធ្នូ ឆ្នាំ២០១៣ | កំពុងរក |
| ៥.២ | ការបែងចែកស្បៀងដោយមានគោលដៅ ដល់ក្រុមងាយរងគ្រោះពិសេស | ក្រ.សុខាភិបាល | អ្នកជម្ងឺរបេង ឆ្នាំ ២០១០ អ្នកជម្ងឺចំនួន ២២.៨៥៧ នាក់ ចំណាយថវិកា ២ លានដុល្លារ<br>អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ ឆ្នាំ ២០១០ ចំនួន ៦៧.៤៦០ នាក់ ចំណាយថវិកា ៤.២លានដុល្លារអាមេរិក | កំពុងរក |
| ៥.៣ | សេវាសុខុមាលភាពសង្គម រួមមាន សុខុមាលភាពកុមារ និងការស្តារនីតិសម្បទាយុវជន សុខុមាលភាព និងការស្តារនីតិសម្បទាសម្រាប់ជនពិការ ប្រជាជនគ្មានផ្ទះសំបែង សុខុមាលភាពសម្រាប់ចាស់ជរា និងអតីតយុទ្ធជន | ក្រ.សង្គមកិច្ច | ផ្នែកលើកម្មវិធីការងារ ឆ្នាំ២០០៨-១៣ របស់ក្រ.សង្គមកិច្ច នៅត្រឹមឆ្នាំ២០១៣ អ្នកទទួលផល នឹងរួមបញ្ចូលកុមារកំព្រា ចំនួន ១១.០០០នាក់ អតីតយុទ្ធជន ចំនួន ១០៥.១៦០ នាក់ និងសមាជិកគ្រួសារ | បានផ្តល់ហិរញ្ញប្បទានដោយថវិកាក្រ.សង្គមកិច្ច |

| កម្មវិធី និងសកម្មភាពអាទិភាពរយៈពេលខ្លី | | ស្ថាប័នអនុវត្ត | ចំនួនប៉ាន់ស្មាននៃគម្រិត និងអ្នកទទួលផល | ស្ថានភាពហិរញ្ញប្បទាន |
|---|---|---|---|---|
| | | | ចំនួន ៣១៦.២៦០នាក់ កុមារ និងយុវជនល្មើសច្បាប់ចំនួន ១៥.១៨៥ នាក់ ជនពិការចំនួន ៤.៥០០ នាក់ (៩០០ នាក់ក្នុងមួយឆ្នាំ) ដែលរួមទាំងកុមារពិការចំនួន ៦៧៦ នាក់ ប្រជាជនគ្មានផ្ទះសំបែងចំនួន ៧.៥០០ នាក់ (១.៥០០ នាក់ ក្នុងមួយឆ្នាំ) ស្ត្រីឆ្លងជម្ងឺអេដស៍ និងកូន និងគ្រួសាររបស់ពួកគេចំនួន ១.៥០០ នាក់ (៣០០ នាក់ ក្នុងមួយឆ្នាំ) ស្ត្រិ និងកុមាររងគ្រោះ ដោយសារការជួញដូរមនុស្សចំនួន ៨.៥០០ នាក់ (ចំនួន ១.៥១០ នាក់ក្នុងមួយឆ្នាំ) | |